**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អគ្គនាយកដ្ឋានការងារ**

**នាយកដ្ឋានអធិការកិច្ចការងារ**

លេខ: ០៧១........កប/អក/អធក

**ជម្រាបជូន**

**លោកឧកញ៉ា ប្រធានសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា**

**កម្មវត្ថុ ៖** ករណីគណនាការឈប់សម្រាកប្រចាំឆ្នាំជាសមាមាត្រ នៅពេលដែលកម្មករនិយោជិតធ្វើកាតិចជាង២១ថ្ងៃក្នុងមួយខែ។

**យោង ៖** លទ្ធផលកិច្ចប្រជុំក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ នាយកដ្ឋានអធិការកិច្ចការងារ សូមធ្វើការបំភ្លឺជូនសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា ជ្រាបថា ការគណនាការឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួល ត្រូវគិតជាសមាមាត្រដូចខាងក្រោម៖

- កម្មករនិយោជិតពេញសិទ្ធិ ដែលបានបំពេញការងារចាប់ពី២១ថ្ងៃ ក្នុងមួយខែ មានសិទ្ធិទទួលបានការឈប់សម្រាកចំនួនមួយថ្ងៃកន្លះ
- កម្មករនិយោជិតពេញសិទ្ធិ ដែលបានបំពេញការងារចាប់ពី១៥ថ្ងៃ ប៉ុន្តែតិចជាង ២១ថ្ងៃក្នុងមួយខែ មានសិទ្ធិទទួលបានការឈប់សម្រាកចំនួនមួយថ្ងៃ
- កម្មករនិយោជិតពេញសិទ្ធិ ដែលបានបំពេញការងារតិចជាង១៥ ថ្ងៃក្នុងមួយខែ ពុំមានសិទ្ធិទទួលបានការឈប់សម្រាកប្រចាំឆ្នាំឡើយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកឧកញ៉ាប្រធាន** មេត្តាជ្រាប និងអនុវត្តតាមការគួរ។

សូម **លោកឧកញ៉ាប្រធាន** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះពីខ្ញុំ។

ថ្ងៃ សុក្រ ១៣កើត ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០២០

**ប្រធាននាយកដ្ឋានអធិការកិច្ចការងារ**

**អ៊ឹក_ចាន់ធូ**

**ចម្លងជូន៖**

- គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា
- ក្រុមប្រឹក្សាអាជ្ញាកណ្តាល
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- សមាគមស្បែកជើងកម្ពុជា